អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០

# សេចក្តីប្រកាសព័ត៌មាន

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានបន្តកិច្ចព្រមព្រៀងជាមួយអង្គការចិត្តសង្គមអន្តរវប្បធម៌ (ហៅកាត់ថា TPO) ក្នុងគោលបំណងចាក់ផ្សាយកម្មវិធីផ្សាយបន្តផ្ទាល់មួយតាមវិទ្យុដែលមានឈ្មោះថា "អតីតក្នុងបច្ចុប្បន្ន"។ កម្មវិធីនេះពិភាក្សាអំពីបញ្ហានានាពាក់ព័ន្ធនឹងជនរងគ្រោះសម័យខ្មែរក្រហម។ កិច្ចព្រមព្រៀងនេះគឺជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការរវាង អ.វ.ត.ក និង TPO ដែលបានដំណើរការតាំងពីឆ្នាំ២០០៩មក ដើម្បីជួយដល់ជនរងគ្រោះពីការប៉ះទង្គិចផ្លូវចិត្ត ក្នុងការប្រឈមមុខនឹងអតីតកាលដ៏គួរឱ្យរន្ធត់ក្រោមរបបខ្មែរក្រហម។ កម្មវិធីនេះនឹងត្រូវចាក់ផ្សាយចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ នៅភ្នំពេញ និងនៅតាមបណ្តាខេត្តចំនួន៨ ទៀត។ កម្មវិធីនេះមានគោលបំណងដូចខាងក្រោម៖

- បង្កើនការយល់ដឹង និងធ្វើឱ្យសាធារណជនកម្ពុជាបានជ្រាបអំពីផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្ត ដោយសាររបបខ្មែរក្រហម។
- ចែករំលែក និងផ្លាស់ប្តូរបទពិសោធន៍ (ពាក់ព័ន្ធនឹងការប៉ះទង្គិចផ្លូវចិត្ត) តាមរយៈការរៀបចំវេទិកាសាធារណៈ។
- ផ្តល់ការគាំទ្រផ្លូវចិត្ត និងមធ្យោបាយនានា ដែលអាចធ្វើឱ្យអ្នកស្តាប់មានលទ្ធភាពដោះស្រាយបញ្ហាសុខភាពផ្លូវចិត្តពាក់ព័ន្ធនឹងអតីតកាលសម័យខ្មែរក្រហម។
- ចងក្រងព័ត៌មានសាធារណៈស្តីពីការវិវឌ្ឍន៍ថ្មីៗនៅ អ.វ.ត.ក សម្រាប់ដើមបណ្តឹង រដ្ឋប្បវេណី និងជនរងគ្រោះនៃរបបខ្មែរក្រហម។

យើងសង្ឃឹមថាកម្មវិធីនេះនឹងទាក់ទាញប្រិយមិត្តឱ្យទូរស័ព្ទចូលរួមដើម្បីចែករំលែកបទពិសោធន៍ និងជំរុញការផ្សព្វផ្សាយសារស្តីពីការព្យាបាល និងការផ្សះផ្សារ ឱ្យបានកាន់តែទូលំទូលាយក្នុងស្រទាប់មិត្តអ្នកស្តាប់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**រាជ សម្បត្តិ**
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទដៃ: +៨៥៥-១២ ៨៨៨ ១៥៦
ទូរសារ: +៨៥៥-២៣ ២១៩ ៨៤១
សារអេឡិចត្រូនិក: reach.sambath@eccc.gov.kh

**ឌីម សុវណ្ណារុំ**
អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥-១២ ៨៨៨ ០៩៤
ទូរសារ: +៨៥៥-២៣ ២១៩ ៨៤១
សារអេឡិចត្រូនិក: dim.sovannarom@eccc.gov.kh